

# ពូជពោត លឿងមង្គល

## Loeung Mongkul




វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

Cambodian Agricultural Research and Development Institute


## ប្រវត្តិរបស់ពូជ

ពូជពោត " លឿងមង្គល " ត្រូវបានរំដោះដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានាចុងឆ្នាំ ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ ( បីឆ្នាំ) កន្លងមក។ ពូជនេះមានប្រភពដើមចេញពីស្រឡាយ COTAXTLA-S0031 របស់វិទ្យាស្ថានស៊ីមីត (CIMMYT) ដែលស្ថិតនៅប្រទេសម៉ិចស៊ិចកូ ។

## លក្ខណៈពិសេសៗរបស់ពូជពោត "លឿងមង្គល"

### លក្ខណៈរូបសាស្ត្រ

ពូជពោត "លឿងមង្គល" មានលក្ខណៈដើមដងរឹងមាំ ស្លឹកមានពណ៌បៃតងចាស់ ហើយដុះលូតលាស់យ៉ាងលឿនបន្ទាប់ពីដាំបាន ១៥-២០ ថ្ងៃ។ ប្រព័ន្ធឫសមានការដុះលូតលាស់យ៉ាងខ្លាំង មានតួនាទីទប់ដើម មិនឱ្យដួលរលំដោយសារខ្យល់ និងនៅពេលដើមចាប់ផ្ដើមស្ងួត ឬងាប់។ ដើមមានកំពស់ជាមធ្យមពី ២ ម៉ែត្រ ទៅ ២,៥ ម៉ែត្រ ។ កំពស់ផ្លែពីដី គឺពី ៨៥ សង់ទីម៉ែត្រទៅ ១ ម៉ែត្រ។ ផ្លែមានរាងទ្រវែង ប្រវែងពី ១៥ សង់ទីម៉ែត្ររហូតដល់ ៣០ សង់ទីម៉ែត្រ។ គ្រាប់មានពណ៌លឿងចាស់ រាងដូចធ្មេញកោងរលោងផ្នែកខាងខ្នង ចំនួនជួររបស់គ្រាប់ក្នុងមួយផ្លែពី ១២-១៦ ជួរ និងទំងន់ ១០០០ គ្រាប់ស្មើនឹង ៣០០ ក្រាម ។





## ទិន្នផល

ពូជពោត "លឿងមង្គល" អាចផ្តល់ទិន្នផលជាមធ្យម ៤,0 តោន ក្នុងមួយហិកតា ប៉ុន្តែក្នុងលក្ខខណ្ឌល្អអាចផ្តល់ផលរហូតដល់ ១0,0 តោន ក្នុងមួយហិកតា ។

## ការប្រើប្រាស់ពូជ

ការដាំដុះពូជពោត " លឿងមង្គល " លើផ្ទៃដី ១ ហិកតា ត្រូវការពូជពី ៣0 ទៅ ៣៥ គីឡូក្រាម ( ដាំ ២-៣ គ្រាប់/គុម្ព) ។

## វិធីសាស្ត្រដាំដុះ

គេអាចធ្វើការដាំដុះដំណាំពោតបានពេញមួយឆ្នាំ ដោយការបុកដាំ ការដាំជាជួរ ឬដាំតាមចង្អូរដូចតារាងខាងក្រោម ។

| ចន្លោះជួរ (ស.ម) | ចន្លោះគុម្ព (ស.ម) | |
|---|---|---|
| | ១ដើម/គុម្ព | ២ដើម/គុម្ព |
| ៦៥ | ៣0 | ៦0 |
| ៧0-៨0 | ២៥ | ៥៥ |
| ៨៥-៩៥ | ២0 | ៤0 |



មុនពេលដាំត្រូវយកគ្រាប់ពូជមកត្រាំទឹកឱ្យបានពី ៤-៦ ម៉ោងដើម្បីឱ្យគ្រាប់រីកឆាប់ដុះ (តំបន់ដែលមានទឹកគ្រប់គ្រាន់) ដោយដាក់គ្រាប់ក្នុងមួយរណ្តៅពី ២-៣ គ្រាប់ និងជម្រៅពី ២-៤ ស.ម ។ នៅរដូវប្រាំង ត្រូវធ្វើការស្រោចស្រពដីឱ្យបានជោគក្រោយពេលដាំ ចំពោះតំបន់ដាំដុះដែលអាស្រ័យទឹកភ្លៀង យើងត្រូវដាំគ្រាប់ស្ងួតដោយមិនចាំបាច់ត្រាំទឹកទេ។ ការកាត់រំលោះដើមគឺអាចធ្វើនៅពេលកូនពោតមានអាយុបាន ១0 -១៥ ថ្ងៃដោយទុកតែមួយដើមក្នុងមួយគុម្ព និងធ្វើការសម្អាតស្មៅឱ្យស្អាតជៀសវាងការប្រជែងស្រូបយកជីជាតិពីដំណាំ ដែលបណ្តាលឱ្យដំណាំក្រិន មិនសូវលូតលាស់ និងផ្តល់ផលតិច ។

## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិ សំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផលនោះក្រោយពីដាំបានចំនួន ៥-៦ ថ្ងៃ គ្រាប់ចាប់ផ្តើមដុះពន្លកទម្លុះដីមកខាងលើ និងក្រោយពីដាំបានចំនួន ១៥-២0 ថ្ងៃ ការដុះលូតលាស់របស់ពូជនេះប្រព្រឹត្តទៅយ៉ាងលឿន និងមានកំពស់ពី ៥0 - ៧0 សង់ទីម៉ែត្រ ដើមថ្លោស ស្លឹកឡើងពណ៌បៃតងចាស់។ ពូជនេះចាប់ផ្តើមចេញផ្កាឈ្មោលនៅពេលបានអាយុកាល ៥១-៥៣ ថ្ងៃក្រោយពីដាំ និងចេញផ្កាញីនៅពេលបានអាយុកាល ៥៣-៥៥ ថ្ងៃក្រោយពីដាំ និងចាប់ផ្តើមទុំនៅរយៈពេល ៩៥-៦0 ថ្ងៃ ក្រោយពីចេញផ្កាញី ។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលាធ្វើឱ្យដំណាំដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់គឺអាសូត ផូស្វ័រ និងប៉ូតាស្យូម ($N : P_2O_5 : K_2O$) ។ កម្រិតនៃប្រើប្រាស់ជី អាចប្រែប្រួលទៅតាមប្រភេទដី។ ការប្រើប្រាស់ជីចែកចេញជាបីដំណាក់កាល គឺដាក់ទ្រាប់បាតមុនពេលដាំ ដោយប្រើប្រាស់ជីអាសូត (៥0%) ផូស្វរ និងប៉ូតាស្យូម(១00%) ចំណែកអាសូតនៅសល់(៥0%) ប្រើសម្រាប់ដាក់បំប៉នចំនួនពីរលើកទៀត គឺលើកទី ១ (២៥%) ក្រោយពីដាំ

បាន ២០-២៥ថ្ងៃ និងបំប៉នលើកទី ២ (២៥%) ក្រោយពីដាំបាន ៤០-៤៥ ថ្ងៃ។ ការដាក់ជី គឺយើងត្រូវដាក់ឱ្យឆ្ងាយពីគល់ពី ១០-១៥ ស.ម រួចពូនដីលប់ឱ្យជិត ដើម្បីទប់គល់ពោតផង និងការពារជីមិនឱ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹក។

| ជី | កម្រិតជីទៅតាមប្រភេទដី (គក្រ/ហត) | | | | |
|---|---|---|---|---|---|
| | ដីខ្សាច់ (ព្រៃខ្មែរ.ប្រទះឡាង) | ដីឥដ្ឋ (កំពង់សៀម) | ដីក្រហម (ឡាបានសៀក) | ដីកណ្តេង (ទួលសំរោង) | ដីល្បាប់ (កៀនស្វាយ) |
| អ៊ុយរ៉េ | ១២៤ | ១៧៤ | ១៧៤ | ១៧៤ | ១៥០ |
| ដេ អា ប៉េ | ៩៥ | ១០៧ | ១០៧ | ១០៧ | ៨៥ |
| ប៉ូតាស្យូម | ៣៧ | ៤៥ | ៤៥ | ៣៧ | ៥៤ |

## ការប្រមូលផល

គេអាចប្រមូលផលពោត នៅពេលដើមពោតចាប់ផ្តើមប្រែពណ៌ពីសំបកក្តាមទៅលឿងស្ងួត ឬងាប់ដើម សំបកផ្លែមានពណ៌លឿងស្ងួតហើយស្រួយ សក់ពោតឡើងស្ងួត ឬសំគាល់មួយផ្នែកទៀតនៅលើគល់របស់គ្រាប់ឡើងពណ៌ប្រផេះគឺនៅពេលពោតបានអាយុកាលពី ១០០-១១០ ថ្ងៃបន្ទាប់ពីដាំ។ ការយឺតយ៉ាវក្នុងការប្រមូលផល នៅរដូវភ្លៀងធ្លាក់ជោគជាំ អាចធ្វើឱ្យផលនៃគ្រាប់ពោតធ្លាក់ចុះ និងបាត់បង់គុណភាពដោយសារទឹកភ្លៀងជ្រាបចូលក្នុងផ្លែបណ្តាលឱ្យគ្រាប់ដុះ ឬកើតជម្ងឺផ្សិតលើគ្រាប់។





## ការទុកក្រោយពេលប្រមូលផល

ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលគឺពី ១៨-២០% ដូច្នេះតម្រូវឱ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកំដៅថ្ងៃ។ ត្រូវឧស្សាហ៍ប្រែត្រឡប់គ្រាប់ខណៈកំពុងហាល ដើម្បីឱ្យគ្រាប់ឆាប់ស្ងួតល្អ។ ការយឺតយ៉ាវក្នុងការហាលសម្ងួត និងទុកដាក់គ្រាប់ពោតមិនបានល្អក្រោយពេលប្រមូលផល អាចធ្វើឱ្យកើតសត្វល្អិតចង្រៃ ដូចជាខ្មូត ជាដើមដែលវាបានស៊ីបំផ្លាញគ្រាប់ពោតតាំងពីនៅលើដើមរហូតដល់គ្រាប់នៅក្នុងកន្លែងរក្សាទុកគ្រាប់ពូជ។ មិនតែប៉ុណ្ណោះអាចធ្វើឱ្យបាត់បង់គុណភាពដូចជា គ្រាប់កើតជម្ងឺផ្សិតធ្យូង គ្រាប់ឡើងផ្សរដែលជាហេតុធ្វើឱ្យតម្លៃគ្រាប់ពោតធ្លាក់ចុះ ។

## ការរក្សាទុកគ្រាប់ពូជ

ពូជពោត " លឿងមង្គល " ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្ទាប់ទៀតបាន មិនដូចពូជពោតអ៊ីប្រ៊ីដទេ ប្រសិនបើយើងដាំដុះវានៅដាច់តែឯងគ្មានពូជពោតផ្សេងនៅក្បែរ។ ការរក្សាគ្រាប់ពូជទុកសំរាប់ប្រើនៅរដូវបន្ទាប់ ត្រូវមានសំណើមពី ១៣-១៥% គឺទុកនៅកន្លែងស្ងួតល្អ ឬរក្សាទុកក្នុងធុងបិទជិត ឬអាចទុកដាក់ដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត ។





រៀបចំដោយ ចង្កោមបណ្តុះពូជជ្រើសរើសវិទ្យា
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)